# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ

ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃដាក់ : ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១

ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា

ភាសាដើម : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Feb-2011, 15:49
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងសំណើសុំរបស់ អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម នៅក្នុងពេលជំនុំជម្រះ

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម ធូ មណី | |

| | | |
|---|---|---|
| សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី: | មេធាវីការពារក្តីជនជាប់ចោទ: | |
| ពេជ អង្គ | លោក សុន អរុណ | លោក ផាត់ ពៅស៊ាង |
| Elisabeth SIMONNEAU FORT | លោក Michiel PESTMAN | កញ្ញា Diana ELLIS |
| | លោក Victor KOPPE | លោក ស សូវាន |
| | លោក អាង ឧត្តម | លោក Jacques VERGÈS |
| | លោក Michael G.KARNAVAS | លោក Phillipe GRECIANO |

# ចម្លើយតប

១. សហព្រះរាជអាជ្ញា ស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូង បដិសេធចោលនូវសំណើសុំរបស់ អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្ម[1] ("មេធាវីការពារក្តី") ដែលបានជូនដំណឹងនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១១ ដោយឈរលើមូលដ្ឋានថាការដាក់នេះមិនត្រឹមត្រូវតាមពេលវេលា។

២. ការទទួលយកភស្តុតាងនៅ អវតក គឺត្រូវធ្វើឡើងស្របតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង។ លើកលែងតែមានបទបញ្ញត្តិផ្សេង រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយកដោយអនុលោមតាមវិធានផ្ទៃក្នុង (វិធាន ៨៧-១)។ អង្គជំនុំជម្រះអាចបដិសេធសំណើសុំដាក់ភស្តុតាងណាមួយបើសិនជាឃើញថាសំណើរសុំនោះ៖ ក) មិនមានពាក់ព័ន្ធ ឬស្រំដែល, ខ) មិនអាចរកបានក្នុងរយៈពេលសមស្រប, គ) មិនសមស្របដើម្បីបញ្ជាក់អង្គហេតុដែលត្រូវអះអាងយកមកបញ្ជាក់, ឃ) ច្បាប់មិនអនុញ្ញាត, ឬ ង) មានបំណងដើម្បីពន្យារនីតិវិធី ឬដែលឥតបានការ។ សេចក្តីសំរេចនេះអាចធ្វើបាន *លុះត្រាតែ* ភស្តុតាងត្រូវបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ដោយភាគីណាមួយ (វិធាន ៨៧-៣) ។

៣. ជាបច្ច័យ ការកំណត់ថាតើភស្តុតាងណាមួយ ត្រូវទទួលយក ឬបដិសេធ អាចធ្វើទៅបាន លុះត្រាតែវាមានប្រយោជន៍ នៅពេលអង្គជំនុំជម្រះសាលាដំបូងមានឱកាសពិនិត្យភស្តុតាង និងស្តាប់ចម្លើយរបស់ភាគីនានា។ ការកំណត់បែបនេះ គឺជាបញ្ហាច្បាប់ *និង* អង្គហេតុ។ ដូចដែលបានដាក់បង្ហាញដោយមេធាវីការពារ ក្នុងសំណើសុំរបស់ពួកគេ ការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងពេលសវនាការរឿងក្តីរបស់ "ឌុច" ចំពោះការទទួលយក ឬការបដិសេធ ភស្តុតាង គឺត្រូវបានធ្វើឡើង បន្ទាប់ពីភស្តុតាងត្រូវបានស្នើសុំឱ្យទទួលយកដោយភាគីនានា ត្រូវបានពិនិត្យដោយអង្គជំនុំជម្រះសាលាដំបូង និងភាគីនានាត្រូវបានស្តាប់ចម្លើយរួចហើយ[2]។

---

[1] "សំណើសុំរបស់ អៀង សារី ប្រឆាំងនឹងការប្រើប្រាស់ភស្តុតាងដែលជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មនៅក្នុងពេលជំនុំជម្រះ", ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E33, ERN 00640260 ។

[2] *សូមមើល ករណី កាំង ហ្កេកអ៊ាវ ហៅ "ឌុច", 001/18-07-2007-ECCC/TC,* សេចក្តីសំរេចចំពោះការស្នើសុំរបស់ភាគីនានាដើម្បីដាក់បញ្ចូលឯកសារមួយចំនួន ចំពោះមុខអង្គជំនុំជម្រះ ស្របតាមវិធានផ្ទៃក្នុង ៨៧(២), ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៩, E176, ERN: 00398394-00398401, កថាខ័ណ្ឌ ៨ ។

៤. ក្នុងករណីនេះ អនុលោមតាមវិធាន ៨០(៣) អង្គជំនុំជម្រះនេះ បានសួរទៅភាគីនានា ដើម្បីឱ្យដាក់បញ្ជីឯកសារ និងវត្ថុតាង ដែលពួកគេបានស្នើសុំឱ្យទទួលយក ឱ្យបានមុនថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០១១។ ដោយធ្វើតាមនេះ វិធាន ៨០(៤) ជាបន្ទាប់មក បានផ្ដល់ដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីបង្គាប់ថារាល់ការជំទាស់ទាំងឡាយទៅនឹងការទទួលយកនូវឯកសារ ឬវត្ថុតាង ទាំងនេះ ត្រូវធ្វើឡើងជាលាយលក្ខអក្សរ ដោយភាគីនានា បន្ទាប់ពីសវនាការបឋម ក្នុងរយៈពេលកំណត់មួយ។ រយៈពេលនេះ ត្រូវផ្ដល់ឱកាសសមស្របមួយ សំរាប់ឱ្យភាគីនានាពិនិត្យនូវបញ្ជីទាំងនេះ ដោយអនុលោមតាម វិធាន ៨០ ។

៥. ជាបច្ច័យ សហព្រះរាជអាជ្ញាស្នើថា សូមបដិសេធសំណើសុំនេះចោល ដោយឈរលើមូលដ្ឋាន ដែលថាវាបានធ្វើឡើងមុនពេលវេលា។ សហព្រះរាជអាជ្ញាក៏សូមស្នើផងដែរថា អង្គជំនុំជម្រះសាលាដំបូង គប្បីបង្គាប់ដូចដែលមានចែងក្នុងវិធាន ៨០(៤) ដើម្បីឲ្យភាគីនានា លើកឡើងរាល់ការជំទាស់ទាំងឡាយណា ក្នុង*ពាក្យពេចន៍ច្បាស់លាស់* អំពីភស្តុតាងដែលបានស្នើឡើងដោយភាគីដទៃទៀត ក្នុងរយៈពេលកំណត់មួយ បន្ទាប់ពីសវនាការបឋម។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |